ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

លេខ៖ ១៦៥/២០២៦ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

លទ្ធផលនៃសន្និសីទថ្នាក់រដ្ឋមន្ត្រីហ្វ្រង់កូហ្វូនី លើកទី៤៨
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៦

នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៦ ព្រះរាជាណាចក្រកម្ពុជាបានធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទថ្នាក់រដ្ឋមន្ត្រីហ្វ្រង់កូហ្វូនីលើកទី៤៨ (48th CMF) នៅរាជធានីភ្នំពេញ ដោយមានការចូលរួមពីគណៈប្រតិភូមកពីសមាជិកចំនួន៨៣ នៃអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី (OIF)។ សន្និសីទនេះត្រូវបានដឹកនាំដោយ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា។

សន្និសីទថ្នាក់រដ្ឋមន្ត្រីហ្វ្រង់កូហ្វូនីលើកទី៤៨ បានពិនិត្យឡើងវិញនូវសកម្មភាពការងាររបស់អង្គការ OIF ក្នុងកិច្ចប្រជុំលើកមុន បានពិភាក្សាផ្លាស់ប្តូរយោបល់លើបញ្ហាមួយចំនួនដែលជាផលប្រយោជន៍រួមនៅក្នុងសហគមន៍OIF ព្រមទាំងបានរៀបចំឯកសារសំខាន់ៗ និងអនុសាសន៍នានា ដើម្បីដាក់ជូនកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ ដែលប្រព្រឹត្តទៅនៅរាជធានីភ្នំពេញ ចាប់ពីថ្ងៃទី១៥ ដល់ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៦ ក្រោមមូលបទ «**រួមគ្នាបន្តកសាងសន្តិភាព ដើម្បីវិបុលភាពរួម និងស្ថិរភាពយូរអង្វែង**» ដើម្បីពិនិត្យ និងសម្រេច។ សន្និសីទបានបញ្ចប់ការរៀបចំឯកសារចំនួនបី ដើម្បីដាក់ជូនកិច្ចប្រជុំកំពូលអនុម័ត រួមមាន៖

- **សេចក្តីថ្លែងការណ៍ទីក្រុងភ្នំពេញ** ដែលកំណត់នូវចក្ខុវិស័យរួមរបស់សហគមន៍ហ្វ្រង់កូហ្វូនី និងទិសដៅសម្រាប់ការពង្រឹងកិច្ចសហប្រតិបត្តិការ សាមគ្គីភាព សន្តិភាព និងការអភិវឌ្ឍប្រកបដោយចីរភាពរវាងរដ្ឋ និងរដ្ឋាភិបាល ជាសមាជិក។
- **សេចក្តីអំពាវនាវទីក្រុងភ្នំពេញស្តីពីការការពារបេតិកភណ្ឌវប្បធម៌ និងការលើកកម្ពស់ភាពចម្រុះនៃវប្បធម៌** ដែលគូសបញ្ជាក់ពីគុណតម្លៃនៃការការពារបេតិកភណ្ឌវប្បធម៌ និងការលើកកម្ពស់ភាពចម្រុះនៃវប្បធម៌ ជាមូលដ្ឋានគ្រឹះសម្រាប់ការយោគយល់គ្នាទៅវិញទៅមក និងសន្តិសហវិជ្ជមាន។
- **សេចក្តីសម្រេចស្តីពីស្ថានភាពវិបត្តិ ការងើបចេញពីវិបត្តិ និងការកសាងសន្តិភាព** ដែលបញ្ជាក់ជាថ្មីអំពីតួនាទីរបស់ហ្វ្រង់កូហ្វូនីក្នុងការបង្ការជម្លោះ ការដោះស្រាយជម្លោះដោយសន្តិវិធី និងការគ្រប់គ្រងវិបត្តិ។ សេចក្តីសម្រេចនេះសង្កត់ធ្ងន់លើការគោរពធម្មនុញ្ញអង្គការសហប្រជាជាតិ

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

ច្បាប់អន្តរជាតិ អធិបតេយ្យ និងបូរណភាពទឹកដីរបស់បណ្តារដ្ឋ។ សេចក្តីសម្រេចនេះក៏បានលើកឡើងពីក្តីបារម្ភចំពោះស្ថានការណ៍នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ និងបានអំពាវនាវឱ្យមានការអនុវត្តសេចក្តីប្រកាសរួមចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥ ឱ្យបានពេញលេញ រួមទាំងការបន្តការងារវាស់វែង និងបោះបង្គោលព្រំដែនរបស់គណៈកម្មការចម្រុះខណ្ឌសីមាព្រំដែនគោក (JBC) ឱ្យបានឆាប់ និងការបង្កើតលក្ខខណ្ឌអំណោយផលសម្រាប់ពលរដ្ឋភៀសសឹក អាចវិលត្រឡប់ទៅកាន់លំនៅឋានរបស់ខ្លួនវិញ។

សន្និសីទក៏បានពិចារណាជាវិជ្ជមានចំពោះសំណើសុំទទួលហាន:ជាអ្នកសង្កេតការណ៍ របស់ប្រទេស Saint Kitts and Nevis និងខេត្ត Manitoba នៃប្រទេសកាណាដា ដើម្បីដាក់ជូនកិច្ចប្រជុំកំពូលសម្រេច។ សន្និសីទបានពិនិត្យលើកិច្ចការស្ថាប័ន រដ្ឋបាល ហិរញ្ញវត្ថុ និងប្រតិបត្តិការរបស់អង្គការ OIF ព្រមទាំងបានសង្កត់ធ្ងន់លើតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព។ សន្និសីទក៏បានគាំទ្របេក្ខភាពសាធារណរដ្ឋបេណាំង (Benin) ក្នុងការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំបន្ទាប់នៃសន្និសីទថ្នាក់រដ្ឋមន្ត្រីនៅឆ្នាំ២០២៧ ផងដែរ។

ការធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទថ្នាក់រដ្ឋមន្ត្រីហ្វ្រង់កូហ្វូនីលើកទី៤៨ និងកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ គឺជាព្រឹត្តិការណ៍ដ៏សំខាន់មួយក្នុងការចូលរួមរបស់កម្ពុជាជាមួយសហគមន៍ហ្វ្រង់កូហ្វូនី។ ការធ្វើជាប្រធានរបស់កម្ពុជា ឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់រាជរដ្ឋាភិបាលចំពោះការទូតពហុភាគី និងការសន្ទនា ការដោះស្រាយជម្លោះដោយសន្តិវិធី ព្រមទាំងការលើកកម្ពស់សន្តិភាព ការគោរពគ្នាទៅវិញទៅមក សមភាព និងកិច្ចសហប្រតិបត្តិការឈ្នះ-ឈ្នះ។ ការណ៍នេះក៏បញ្ជាក់ពីការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការពង្រឹងចំណងទាក់ទងជាមួយបណ្តាប្រទេសហ្វ្រង់កូហ្វូនី នៅក្នុងទ្វីបទាំងប្រាំ ការអភិរក្សបេតិកភណ្ឌវប្បធម៌ ការលើកកម្ពស់ភាពចម្រុះនៃវប្បធម៌ និងកិច្ចសហប្រតិបត្តិការផ្នែកភាសា ព្រមទាំងការកសាងសហគមន៍ហ្វ្រង់កូហ្វូនីមួយ ដែលកាន់តែរឹងមាំ មានសាមគ្គីភាពជាងមុន និងមានសមត្ថភាពឆ្លើយតបបានកាន់តែប្រសើរ៕

ថ្ងៃអាទិត្យ ៦កើត ខែកត្តិក ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៦